មជ្ឈមណ្ឌលឯកសារកម្ពុជា

BBI0075

# សម្ភាសន៍ជាមួយឈ្មោះ ស្វាយ ប៊ុត ភេទប្រុស អាយុ៧៦ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម“ចុងភៅ”

## រស់នៅភូមិស្វាយជ្រុំ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង ។

## ថ្ងៃទី១៩ ខែមិនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ស សេងគា

## ០០:៤១:៥៧

## ២៥ទំព័រ

សេងគាៈ ចឹងខ្ញុំចង់សម្ភាសតែមុននិងសម្ភាសខ្ញុំប្រាប់ឈ្មោះខ្ញុំឲ្យអ៊ឹបានស្គាល់សិន ខ្ញុំឈ្មោះសេងគា ។

ប៊ុនៈ ឈ្មោះ សេងគា ។

សេងគាៈ បាទ!ខ្ញុំរស់នៅខេត្តបាត់ដំបងដែរអ៊ឹណាស់ ខ្ញុំជាអ្នកស្រុកបាត់ដំបងបាទ ហើយខ្ញុំការនៅអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា បាទ!មិនមែនជាគណបក្សទេ គឺជាអង្គការទេ អ៊ឹណាស់ ។

ប៊ុនៈ អង្គការដើរសម្ភាសចឹង ។

សេងគាៈ បាទ ។

ប៊ុនៈ សម្ភាសគ្រប់ស្រុកគ្រប់ខេត្ត ។

សេងគាៈ បាទ!សួរនាំចង់ដឹងពីជីវប្រវត្តិផ្ទាល់ខ្លួនរបស់អ៊ឹដែលអ៊ឹធ្លាប់ឆ្លងកាត់តាំងពីសម័យមុនៗមករហូតអ៊ឹណាស់?

ប៊ុនៈ បាទ ។

សេងគាៈ ព្រោះអីខ្ញុំកើតមិនទាន់ទេ ហើយក្មេងៗជំនាន់ក្រោយទៀតក៏មិនសូវជាជឿប៉ុន្មានដែលអ៊ឹណាស់ ប្រាប់ហើយមិនជឿចឹងទាល់តែមានជាឯកសារមានរូបពិតមានជាសម្លេងដើម្បីឲ្យវាបានស្គាល់បានដឹង ចឹងខ្ញុំចង់សុំអ៊ឹសម្ភាសនិងមានអាត់ជាសម្លេងចឹង?

ប៊ុនៈ បាទ ។

សេងគាៈ ចឹងខ្ញុំយកទៅប្រើប្រាស់អ៊ឹមិនថាអីទេ?

ប៊ុនៈ បាទ!មានថាអី ។

សេងគាៈ ចឹងខ្ញុំចង់ស្គាល់ឈ្មោះអ៊ី អ៊ឹឈ្មោះអីដែរ?

ប៊ុនៈ ស្វាយ ប៊ុត ។

សេងគាៈ អ៊ឹអាយុប៉ុន្មានហើយ?

Documentation Center of Cambodia ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
Searching for the Truth: Memory & Justice
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ប៊ុនៈ អាយុ៧៦ ។

សេងគាៈ ៧៦ឆ្នាំ?

ប៉ាទ ។

សេងគាៈ កាលសម័យខ្មែរក្រហមអ៊ំធ្វើអីដែលជាទាហានជាទ័ពដែលឬជាប្រជាជនធម្មតាទេឬជាប្រជាជនមូលដ្ឋាន?

ប៊ុនៈ ធ្វើធម្មតាមក ។

សេងគាៈ ចឹងទេ បច្ចុប្បន្នធ្វើអីអ៊ំ?

ប៊ុនៈ ជំនាន់ហ្នឹងធ្វើប្រាំងធ្វើស្រែហ្នឹង ។

សេងគាៈ ធ្វើស្រែអត់មានធ្វើអាចារ្យវត្តទេ?

ប៊ុនៈ អត់ទេ មកនេះគ្រាន់តែសុំសីលទៅវត្តអីហ្នឹង ។

សេងគាៈ មិនដែលបានធ្វើអាចារ្យទេ?

ប៊ុនៈ មិនដែលទេ ។

សេងគាៈ ខ្ញុំចង់ស្គាល់ឈ្មោះឪពុកអ៊ំឈ្មោះអីដែលអ៊ំ?

ប៊ុនៈ ឪពុក ។

សេងគាៈ ប៉ាទ ។

ប៊ុនៈ ស្វាយ ប៊ុតហ្នឹងឪពុកខ្ញុំហ្នឹងហើយ ។

សេងគាៈ ប៊ុះអ៊ំ?

ប៊ុនៈ ប៊ុតហ្នឹង ។

សេងគាៈ ចឹងឪពុកអ៊ំឈ្មោះស្វាយ?

ប៊ុនៈ ឈ្មោះស្វាយ ។

សេងគាៈ តែត្រកូលគាត់ឈ្មោះអី?

ប៊ុនៈ ឪពុកគាត់មិនចាំព្រោះគាត់ស្លាប់យូរហើយណាស់ ។

សេងគាៈ ចឹងម្ដាយអ៊ំ?

ប៊ុនៈ ម្ដាយឈ្មោះស៊ីម ។

សេងគាៈ តែមិនចាំត្រកូលទេ?

ប៊ុនៈ មិនចាំត្រកូលទេ ។

សេងគាៈ ចឹងប្រពន្ធអ៊ំឈ្មោះអីអ៊ំ?

ប៊ុនៈ ឈ្មោះ ម៉ន ។

សេងគាៈ ស្អីម៉នអឺ ?

ប៊ុនៈ វាក្មេចយូរហើយ ។

សេងគាៈ ប្រពន្ធអ៊ំនៅរស់ឬមួយស្លាប់ហើយ ?

ប៊ុនៈ ស្លាប់ហើយ ។

សេងគាៈ ចឹងមកស្លាប់នៅនេះទេ?

ប៊ុនៈ បាទ ។

សេងគាៈ ទើបស្លាប់ទេ?

ប៊ុនៈ ស្លាប់ចូល១០ឆ្នាំជាងហើយ ។

សេងគាៈ គាត់កើតអីឈឺអ៊ំ?

ប៊ុនៈ ឈឺអីគោយន្តធ្លាក់អូរ ។

សេងគាៈ យ៉ាងម៉េចអ៊ំ?

ប៊ុនៈ ស៊ុំគោយន្តគេជិះ ស៊ុំគោយន្តគេជិះគេចាក់សាំង គេដាក់លេខថយក្រោយអូរនៅប្រហែល ផ្ទះហ្នឹង ។

សេងគាៈ បាទ ។

ប៊ុនៈ អូរនៅចឹងគេថយមកធ្លាក់ចៅមួយ ។

សេងគាៈ ជាមួយចៅ?

ប៊ុនៈ បាទ!ជាមួយចៅ ។

សេងគាៈ ធ្លាក់ចូលអូរទៅ?

ប៊ុនៈ បាទ! ធ្លាក់ចូលអូរទៅចៅត្រូវនិងលូ គេដាក់លូឆ្លងទៅម្ខាងទៀតណាស់ ។

សេងគាៈ ស្លាប់ទាំងពីរនាក់ទៅ?

ប៊ុនៈ អត់ទេ ប្រពន្ធខ្ញុំបាក់ក្មៅនេះ ។

សេងគាៈ បាទ ។

ប៊ុនៈ បាក់ចឹង ។

សេងគាៈ ចឹងស្រុកកំណើតអ៊ំនៅ?

ប៊ុនៈ នៅខេត្តកំពង់ចាម ស្រុកស្គន់ ។

សេងគាៈ ភូមិអីភូមិ?

ប៊ុនៈ ភូមិព្រែកចារ ស្រុកជើងព្រៃ ។

សេងគាៈ ឃុំ?

ប៊ុនៈ ឃុំស្គន់ហ្នឹង ។

សេងគាៈ ស្រុកជើងព្រៃឬឃុំជើងព្រៃ?

ប៊ុនៈ ឃុំជើងព្រៃមើលស្រុកស្គន់ ហីចឹងហើយស្រុកស្គន់ ឃុំព្រែកចារ ។

សេងគាៈ ចឹងបច្ចុប្បន្នមកនៅភូមិស្វាយ?

ប៊ុនៈ ភូមិស្វាយជ្រំជាប់ផ្ទះប្រធានភូមិ ។

សេងគាៈ ឃុំអូរដារ?

ប៊ុនៈ ឃុំអូរដារ ស្រុកកំរៀង ។

សេងគាៈ បានប្រហែល១០ឆ្នាំ?

ប៊ុនៈ បាទ!បាន១០ឆ្នាំ ស្រុកកំរៀង ខេត្តបាត់ដំបង ។

សេងគាៈ បាទ!ចឹងចង់សួរទាក់ទងរឿងរ៉ាវកាលអីនៅពីក្មេងអី ចឹងពីក្មេងអីចូលរៀននៅឆ្នាំណាអាយុប៉ុន្មានដែរ?

ប៊ុនៈ អត់បានចូលរៀន ។

សេងគាៈ អត់បានចូលរៀនទេ?

ប៊ុនៈ ឪពុកយកទៅនេសាទ ។

សេងគាៈ ចឹងទៅរកនេសាទ?

ប៊ុនៈ បាទ ។

សេងគាៈ មិនបានរៀនសោះ?

ប៊ុនៈ បានដែលតែអត់បានចេះ គាត់ចេះតែយកទៅដាក់ទូកអំទូក ។

សេងគាៈ ចឹងឪពុកអីជាអ្នកនេសាទ?

ប៊ុនៈ នេសាទចិញ្ចឹមគ្រួសារនោះ ។

សេងគាៈ បាទ ។

ប៊ុនៈ គាត់យកទៅតាមទូកនិងទៅអត់បានរៀន គាត់ទៅម្នាក់ឯងគាត់ខ្លាចពួកហ្នឹងចាប់ ។

សេងគាៈ ដល់ចឹងទៅក៏ទៅជាមួយគាត់ខានរៀនខាតសូត្រទៅ?

ប៊ុនៈ បាទ!ខានរៀនខានសូត្រទៅ ។

សេងគាៈ តែមានបានរៀនមួយឆ្នាំពីរឆ្នាំដែរ?

ប៊ុនៈ អត់បានរៀន ។

សេងគា: ចឹងអត់បានរៀនសោះតែម្ដង?

ប៊ុនៈ រៀនបានពីរខែ ។

សេងគា: រៀនបានពីរខែ?

ប៊ុនៈ រៀនបានពីរខែនៅសាលាវត្តរៀននៅកុដ គាត់ថាឯងទៅតាមអញទៅ ទៅតាមគាត់រហូត ។

សេងគា: ចឹងអីនៅស្កូនរហូត?

ប៊ុនៈ នៅតែរហូតហ្នឹង ។

សេងគា: ចឹងសម័យកុម្មុយនីស្តនិយមអីអ៊ំធ្វើអីកាលហ្នឹង?

ប៊ុនៈ មានធ្វើអី?

សេងគា: ទៅនេសាទជាមួយឪពុកទៅ?

ប៊ុនៈ បាទ! ធ្វើស្រែធ្វើប្រាំងហើយឪពុកខ្ញុំនិងគាត់រកត្រីអីណាស់ ។

សេងគា: ចឹងដល់ពេលឆ្នាំ៧០នោះអ៊ំ ឆ្នាំរដ្ឋប្រហាលន់ នល់នោះ លន់ នល់ធ្វើរដ្ឋប្រហានៅពេលហ្នឹង ធ្វើអីអ៊ំ?

ប៊ុនៈ ពេលហ្នឹងធ្វើខ្ញុំគេតែម្ដងធ្វើបឹង ។

សេងគា: ធ្វើបឹងអ៊ំ?

ប៊ុនៈ បាទ! គេហៅទៅធ្វើណាស់ ។

សេងគា: បាទ ។

ប៊ុនៈ គេហៅទៅធ្វើជាកម្មករគេទេ មិនមានមេការអីទេប្រាក់ខែយើងប្រាំពីរម៉ឺនណាស់ ។

សេងគា: បាទ ។

ប៊ុនៈ ដល់ពេលចាប់ត្រីហ្នឹងគេអូសអួន ។

សេងគា: ចឹងនៅពេលមានរដ្ឋប្រហារអត់មានរត់ទៅណាទេ មានទម្លាក់គ្រាប់បែកអត់មានរត់ទេ?

ប៊ុនៈ អត់មានរត់ទៅណា ។

សេងគា: នៅតែផ្ទះហ្នឹងតែម្ដង?

ប៊ុនៈ បាទ! ខ្ញុំនិយាយមិនអស់ដងដង "ស្ដាប់មិន......" ។

សេងគា: ចឹងកាល៧០ហ្នឹងមកនៅហ្នឹងវិញ?

ប៊ុនៈ ទេ ឈប់សិនពីដើមមកនិយាយខក ។

សេងគា: បាទ ។

ប៊ុនៈ		កាលណីដើមខ្ញុំនៅក្រចេះនៅដាំដំណាំណាស់ ។

សេងគាៈ		បាទ ។

ប៊ុនៈ		ក្រោយមកខ្ញុំមករកត្រីគេនៅចឹងកក់ ម៉ាឃុំយើងហ្នឹងមានតែកន្ទែងហ្នឹងធំជាងគេ សុទ្ធតែត្រីរស់ទៅរកធ្វើលបដាក់និងទៅដាក់លបនៅសាទហ្នឹងជំនាន់សង្គមយើងមួយគីឡូរពីដបមួយពាន់ពីររយដាក់ហ្នឹងទៅជាមួយប្រពន្ធដល់ចឹង ។

សេងគាៈ		អ៊ំរៀបការនៅឆ្នាំណា?

ប៊ុនៈ		យូរហើយ ។

សេងគាៈ		រៀបការតាំងពីអាយុប៉ុន្មានអ៊ំ?

ប៊ុនៈ		អាយុប្រហែលជា២៦ ។

សេងគាៈ		២៦តាំងពីសម័យសង្គមរាស្ត្រនិយម?

ប៊ុនៈ		បាទ!តាំងពីជំនាន់ហ្នឹងនោះ ។

សេងគាៈ		ចឹងអ៊ំមានកូនប៉ុន្មាននាក់ចឹង?

ប៊ុនៈ		មានកូនពីរកូនបងស្លាប់ហើយសព្វថ្ងៃនៅមីស្រីមួយ ។

សេងគាៈ		ចឹងមានកូនតែពីរនាក់ទេ ប្រុសមួយស្រីមួយ?

ប៊ុនៈ		បាទ!នៅមីស្រីបងវាស្លាប់ ។

សេងគាៈ		កូនទី១ឈ្មោះអីអ៊ំ?

ប៊ុនៈ		កូនទី១ឈ្មោះ ប៊ុន ។

សេងគាៈ		ឈ្មោះអីប៊ុនអ៊ំ?

ប៊ុនៈ		ប៊ុត ប៊ុន ។

សេងគាៈ		ស្លាប់អ៊ំណឹង?

ប៊ុនៈ		ស្លាប់ ។

សេងគាៈ		ស្រី?

ប៊ុនៈ		ហ្នឹងប្រុសស្រីនៅ ។

សេងគាៈ		ចឹងនៅកូនស្រីឈ្មោះអី?

ប៊ុនៈ		ឈ្មោះ ម៉ុន ។

សេងគាៈ		ចឹងចង់ដឹងប្រវត្តិអ៊ំពីដើមអ៊ំជាអ្នកស្រុកស្អន់?

ប៊ុនៈ		បាទ ។

សេងគា៖	បន្ទាប់មកអ៊ំទៅរកស៊ីនៅក្រចេះ?

ប៊ុន៖	បាទ!នៅក្រចេះ ។

សេងគា៖	ចឹងមានប្រពន្ធហើយបានទៅរកស៊ីនៅក្រចេះ?

ប៊ុន៖	បាទ!មានហើយការហើយបានទៅរកហ្នឹងទៅជាមួយបង ។

សេងគា៖	បាទ ។

ប៊ុន៖	បងមកស្លាប់ទៅបង ។

សេងគា៖	ចឹងអ៊ំមានបងប្អូនប៉ុន្មាន?

ប៊ុន៖	បងប្អូនមាន៦ទៅ៧នាក់នៅអីស្រុកនោះ  នៅគ្មានទេ ។

សេងគា៖	ចឹងបងប្អូន៧នាក់?

ប៊ុន៖	៧នាក់ ។

សេងគា៖	ប្រុសប៉ុន្មានស្រីប៉ុន្មានអ៊ំ?

ប៊ុន៖	ប្រុស៣ស្រី២អេស្រី៣ ។

សេងគា៖	ចឹងប្រុស៣ស្រី៣ចឹងមាន៦នាក់?

ប៊ុន៖	បាទ!ស្លាប់មួយនៅ៦ ។

សេងគា៖	ស្លាប់និងប្រុសស្រីអ៊ំ?

ប៊ុន៖	ស្លាប់ស្រីស្លាប់បងគេ ។

សេងគា៖	ចឹងស្រី៤អ៊ំ?

ប៊ុន៖	បាទ!ស្រី៤ ។

សេងគា៖	កូនទី១ឈ្មោះអីអ៊ំ  អះ!បងអ៊ំបងទី១?

ប៊ុន៖	បងទី១ឈ្មោះ  សុំ ។

សេងគា៖	ទី២?

ប៊ុន៖	ឈ្មោះ  ស៊ិន ។

សេងគា៖	ទី៣?

ប៊ុន៖	ឈ្មោះ  មុត ។

សេងគា៖	ទី៤?

ប៊ុន៖	ឈ្មោះ  ណូ  តែស្លាប់អស់ហើយ ។

សេងគា៖	បាទ!ទី៥?

ប៊ុនៈ ទី៥ខ្ញុំហ្នឹង ។

សេងគាៈ ទី៦?

ប៊ុនៈ ទី៦ឈ្មោះអីទេ ស្លាប់យូរហើយគាំងពីតូចបងគេនោះមិនដឹងជាឈ្មោះអីដែលវាមិនចាំ ។

សេងគាៈ ចឹងអត់ចាំ?

ប៊ុនៈ បាទ ។

សេងគាៈ ចឹងទី៧ ។

ប៊ុនៈ ទី៧ហ្នឹងអត់ចាំដែរ ។

សេងគាៈ ចឹងបងប្អូនអ៊ីស្លាប់អស់ហើយ?

ប៊ុនៈ ស្លាប់អស់ហើយ ។

សេងគាៈ នៅសល់តែអ៊ីមួយទេ?

ប៊ុនៈ បាទ!នៅសល់តែខ្ញុំ ។

សេងគាៈ គាត់ស្លាប់សម័យប៉ុល ពតឬទើបនិងស្លាប់?

ប៊ុនៈ ស្លាប់ដោយសារជំងឺ ។

សេងគាៈ ស្លាប់ជំងឺក្រោយទេអ៊ី?

ប៊ុនៈ បាទ!ហើយបងមួយនោះស្លាប់សម័យខ្មែរក្រហម ។

សេងគាៈ ចឹងអ៊ីនៅក្រចេះរហូតដល់មានការទម្លាក់គ្រាប់បែក?

ប៊ុនៈ បាទ!ទម្លាក់គ្រាប់បែកហើយខ្ញុំនៅត្រពាំងផ្លុងវិញ ។

សេងគាៈ ចឹងចេញពីក្រចេះមកពេលទម្លាក់គ្រាប់បែកអ៊ីមកត្រពាំងផ្លុងវិញ?

ប៊ុនៈ បាទ!ត្រពាំងផ្លុងវិញ ត្រពាំងផ្លុងនេះគ្រាប់ផ្លោងយួនចេញមកនៅអូររាំងឪនេះ ។

សេងគាៈ កាលនៅក្រចេះអ៊ីនៅកន្លែងណា?

ប៊ុនៈ ក្រចេះនៅព្រែកតាអាំ ។

សេងគាៈ ភូមិអីគេ?

ប៊ុនៈ ភូមិព្រែកតាអាំ ។

សេងគាៈ នៅក្រចេះឃុំអីគេ?

ប៊ុនៈ នៅក្រចេះខ្ញុំមិនសូវស្គាល់ដែលហ្នឹង ។

សេងគាៈ មិនដឹងទេ តែស្រុកអី?

ប៊ុនៈ ស្រុកហ្នឹងខ្ញុំនៅព្រែកតាអាំហ្នឹងនៅព្រែកជ្រូក ។

សេងគា៖ ព្រែកជ្រូក?

ប៊ុន៖ បាទ! ព្រែកជ្រូក ស្រុកកញ្ជរជាប់គ្នាហ្នឹង ។

សេងគា៖ បាទ ។

ប៊ុន៖ យើងឆ្លងប្រហែលពីនិងទៅផ្ទះខ្ញុំហ្នឹងមិនដល់ផងទេ ។

សេងគា៖ នៅរយៈពេលហ្នឹងរហូតកាលទៅក្រចេះនិងនៅឆ្នាំណាអ៊ីំ?

ប៊ុន៖ មិនដឹងជាឆ្នាំណា ។

សេងគា៖ ទៅបានប៉ុន្មានឆ្នាំដែលទៅនៅក្រចេះហ្នឹង?

ប៊ុន៖ ខ្ញុំទៅនៅប្រហែលជាចូល១០ដាងហើយ ។

សេងគា៖ បាទ ។

ប៊ុន៖ តាំងពីរដ្ឋប្រហាហ្នឹងខ្ញុំបែកបាក់ពីហ្នឹងមក មកនៅត្រពាំងផ្លុងហ្នឹង ។

សេងគា៖ បាន១០ឆ្នាំដល់មានរដ្ឋប្រហាមក?

ប៊ុន៖ បានខ្ញុំដកខ្លួនចេញ ។

សេងគា៖ ដកខ្លួនចេញមកនៅត្រពាំងផ្លុង?

ប៊ុន៖ បាទ! នៅត្រពាំងផ្លុង ។

សេងគា៖ យ៉ាងម៉េចបានជាអ៊ីំចេញពីហ្នឹង ទម្លាក់គ្រាប់បែកនៅមិនបាន?

ប៊ុន៖ បាទ ។

សេងគា៖ ចឹងរត់មកទាំងប្រពន្ធកូន?

ប៊ុន៖ មកទាំងអស់ទាំងកូនទាំងចៅទាំងអស់ រត់មកនៅហ្នឹង ។

សេងគា៖ កាលហ្នឹងឪពុកអ៊ីំមកនៅជាមួយដែលអត់ទេ?

ប៊ុន៖ អត់ទេ ។

សេងគា៖ ទៅតែប្ដីប្រពន្ធអ៊ីំទេ?

ប៊ុន៖ អូស! នៅគាត់មកស្លាប់នៅផ្ទះនៅស្រុកណាស់ ព្រែកចារហ្នឹង ។

សេងគា៖ គាត់នៅព្រែកចារទេ គាត់អត់បានទៅក្រចេះជាមួយអ៊ីំទេ?

ប៊ុន៖ ទៅជាមួយគ្នា ។

សេងគា៖ ចឹងទៅជាមួយគ្នា?

ប៊ុន៖ បាទ! នៅជាមួយគ្នា ។

សេងគា៖ ទៅរកស៊ីទាំងអស់គ្នាអ៊ីំ?

ប៊ុនៈ ទៅរកស៊ីគាត់ធ្វើលបធ្វើលាយណាស់ ។

សេងគាៈ បាទ! នៅត្រពាំងផ្ទុងហ្នឹងនៅភូមិអីឃុំអីអឹ?

ប៊ុនៈ ត្រពាំងផ្ទុង ។

សេងគាៈ បាទ ។

ប៊ុនៈ ឃុំត្រពាំងផ្ទុងតែម្តង ខេត្តកំពង់ចាមហ្នឹង ស្រុកពញាក្រែក ។

សេងគាៈ មកនៅហ្នឹងរត់មកនៅហ្នឹងបានប៉ុន្មានឆ្នាំអឹ កាលរត់មកជិះអីមកអឹ?

ប៊ុនៈ ជិះអូសរម៉ក ។

សេងគាៈ អូសរម៉ក?

ប៊ុនៈ រម៉កយើងធម្មតាហ្នឹងរម៉កកង់ ។

សេងគាៈ ពីណាគេជាអ្នកធាក់មក?

ប៊ុនៈ ខ្ញុំ ។

សេងគាៈ អឹអ្នកធាក់រម៉កមក?

ប៊ុនៈ អើយហ្នឹងហើយ ។

សេងគាៈ ចឹងធាក់រម៉កមកនៅហ្នឹងទៅ នៅពញាក្រែកហ្នឹងទៅ?

ប៊ុនៈ បាទ! នៅប្រហែលជាបីឆ្នាំ ។

សេងគាៈ នៅបានបីឆ្នាំ?

ប៊ុនៈ បាទ ។

សេងគាៈ ចឹងមានតែ៧៣អឹ?

ប៊ុនៈ បាទ! ៧៣ ។

សេងគាៈ ចឹង៧៣អឹទៅណាទៀត?

ប៊ុនៈ ដល់៧៣មកនៅអូររាំងឪ ។

សេងគាៈ បាទ ។

ប៊ុនៈ នៅអូររាំងឪប្រហែលជាបីឆ្នាំដែរ ថាបីឆ្នាំចុះព្រោះខ្ញុំវាភ្លេចយូរហើយណាស់ ។

សេងគាៈ ចឹងនៅកន្លែងស្រុកអូររាំងឪតែម្តងអឹ?

ប៊ុនៈ បាទ! នៅស្រុកអូររាំងឪឃុំអំពិលតាពក ។

សេងគាៈ ឃុំអំពិលតាពក?

ប៊ុនៈ បាទ! ស្រុកឆ្លូង ។

សេងគាៈ អូររាំងឪកំពង់ចាម?

ប៊ុនៈ បាទ ។

សេងគាៈ ចឹងយ៉ាងម៉េចបានជាអ៊ំចេញមកពីស្រុកដូងអ៊ី?

ប៊ុនៈ រឿងមកនៅហ្នឹងមានគ្រាប់ផ្លោងអាមិចអី ។

សេងគាៈ ចឹងអាមិចគ្រាប់ផ្លោងនៅអត់បានរត់មក?

ប៊ុនៈ បាទ ។

សេងគាៈ អត់មានគេជម្លៀសអីទេ រត់មកខ្លួនឯង?

ប៊ុនៈ អត់មានគេជម្លៀសទេធម្មតា ។

សេងគាៈ ចឹងរត់មកនៅអូររាំងឪបានបីឆ្នាំដែរ?

ប៊ុនៈ បាទ!បីឆ្នាំ ។

សេងគាៈ ចឹងបីឆ្នាំទៀតចូល៧៦ហើយ?

ប៊ុនៈ បាទ!៧៦ ។

សេងគាៈ ដល់៧៦ហ្នឹងខ្មែរក្រហមចូលហើយអ៊ី?

ប៊ុនៈ ចូលហើយ ។

សេងគាៈ ហើយអ៊ំនៅអូររាំងឪហ្នឹងទៅ?

ប៊ុនៈ នៅអូររាំងឪដល់និងសុំគេប្រធាន ។

សេងគាៈ សុំប្រធានប្រធានឈ្មោះអីអ៊ំ?

ប៊ុនៈ មិនដឹងឈ្មោះខ្ញុំមិនស្គាល់ឈ្មោះដែរ សុំគេមកស្រុក ។

សេងគាៈ សុំមកស្រុកវិញហើយក៏មកស្រុកវិញទៅ?

ប៊ុនៈ បាទ!មកស្រុកវិញទៅ កាលហ្នឹងដើរអត់មានឡានជិះទេ ។

សេងគាៈ ចឹងដើរទាំងអស់គ្នាមក?

ប៊ុនៈ បាទ!ដើរទាំងអស់គ្នាមក ។

សេងគាៈ ដើរពីហ្នឹងមកមានគ្រាប់កាំភ្លើងបាញ់ទេ កាលហ្នឹង?

ប៊ុនៈ អត់ទេ ។

សេងគាៈ អត់ទេ ស្វាត់អ៊ំណឹង?

ប៊ុនៈ ស្វាត់ឈឺងដូចយប់ចឹង ដើរមួយយប់មួយថ្ងៃមកដបូងមកដេកយើងកំពង់ចាម ។

សេងគាៈ បាទ ។

ប៊ុនៈ កំពង់ចាមទន្លេបិតមកកាលហ្នឹងឆ្លងទូកកាណូតណាស់ ឆ្លងហើយមកដេកហ្នឹងមួយយប់ទៅ ។

សេងគាៈ ចឹងឆ្លងមកដេកនៅកំពង់ចាមមួយយប់ទៅ បានប៉ុន្មានថ្ងៃបានមកដល់កន្លែងមកដល់ផ្ទះ?

ប៊ុនៈ ដើរមួយថ្ងៃហ្នឹងមកដល់ព្រៃទទឹងហ្នឹងមកសម្រាកនៅព្រៃទទឹងហើយ ។

សេងគាៈ បាទ ។

ប៊ុនៈ ដើរពីព្រៃទទឹងទៅ ទៅដេកនៅតាក្រិតមួយយប់ហ្នឹងស្រុកកំណើតក្តួយខ្ញុំដេកនៅហ្នឹងមួយយប់ដល់ដេកហ្នឹងមួយយប់ហើយបានទៅលើដល់ព្រែកចារ ព្រែកចារហ្នឹងនៅហ្នឹងហើយអត់មានទៅណាទេ ។

សេងគាៈ ចឹងកូនប្រុសអ៊ឹស្លាប់នៅពេលណាចឹង?

ប៊ុនៈ ស្លាប់ពេលវាចូលទៅជាមួយបងវា វាចូលអាយុពី១២ តែ១២ធំដែរ ។

សេងគាៈ បាទ ។

ប៊ុនៈ ចូលមុនប្អូនវាចូលនៅត្រពាំងផ្លុង ។

សេងគាៈ ចូលធ្វើអីអ៊ឹ?

ប៊ុនៈ ចូលធ្វើខ្មែរក្រហម ។

សេងគាៈ ចឹងកូនប្រុសអ៊ឹចូលធ្វើទាហានខ្មែរក្រហម?

ប៊ុនៈ ហ្នឹងហើយ ។

សេងគាៈ ស្លាប់អ៊ឹមានដឹងដំណឹងទេ ឬបាត់ឈឹងរហូត?

ប៊ុនៈ ប្អូនវាដឹងថាគេវ៉ៃ ។

សេងគាៈ ប្អូនមួយណា?

ប៊ុនៈ អះ!បងវាហ្នឹងបងអាប្រុសហ្នឹង ។

សេងគាៈ បងប្រុសអ្នកស្លាប់អ៊ឹ?

ប៊ុនៈ បងប្រុសវាអ្នកស្លាប់ មីស្រីនៅសព្វថ្ងៃនៅនេះ ។

សេងគាៈ ចឹងស្រីហ្នឹងចូលធ្វើទាហានដែរ?

ប៊ុនៈ អត់ទេ ចូលខ្មែរក្រហមដែលចូលនៅស្រុកនោះ ។

សេងគាៈ តែកូនបងចូលម៉េចបានអ៊ឹដឹងថាស្លាប់?

ប៊ុនៈ ស្លាប់បងវាដឹងអះ!ប្អូនវាដឹង ។

សេងគាៈ ប្អូនដឹង?

ប៊ុនៈ បាទ ។

សេងគា:	ម៉េចបានដឹង?

ប៊ុន:	វាចូលទៅជួបគ្នាទៅជាមួយគ្នា ។

សេងគា:	ចឹងប្អូនស្រីចូលដែរ?

ប៊ុន:	ប្អូនស្រីចូលនៅខេត្តកំពង់ចាមនិងទេ ។

សេងគា:	បាទ ។

ប៊ុន:	ចូលដេកព្រៃយើងចឹង ។

សេងគា:	ហើយប្រាប់អ៊ំថាកូនប្រុសអ៊ំស្លាប់?

ប៊ុន:	បាទ ។

សេងគា:	កាលហ្នឹងស្លាប់នៅឆ្នាំណាអ៊ំ ចូលខ្មែរក្រហមបានប៉ុន្មានឆ្នាំហើយ៧៦អ៊ំមកស្គន់វិញហើយ?

ប៊ុន:	បាទ!ខ្ញុំមកស្គន់ ។

សេងគា:	មកស្គន់បានប៉ុន្មានឆ្នាំបានប៉ុន្មានខែ?

ប៊ុន:	មើលប្រហែលជា១០ឆ្នាំជាងហើយ ។

សេងគា:	និយាយថាកូនអ៊ំស្លាប់នៅនោះកូនប្រុស?

ប៊ុន:	នៅភ្នំដងរែកនោះ ។

សេងគា:	អ៊ី!ធ្វើទាហាននៅហ្នឹងស្លាប់ ដឹងដំណឹងមកថាស្លាប់ចឹងទៅឆ្នាំ៧៦ហ្នឹង?

ប៊ុន:	បាទ!ឆ្នាំ៧៦ -៧៧ហ្នឹង ។

សេងគា:	តែអ៊ំមានបានឃើញសាកសពទេអត់ទេ?

ប៊ុន:	អត់ទេ ។

សេងគា:	ចឹងគ្រាន់ឮថាស្លាប់ទេ?

ប៊ុន:	បាទ ។

សេងគា:	ចឹងចំណែកអ៊ំវិញគេយកទៅដល់ណាដែលពេលមកដល់ផ្ទះហើយ?

ប៊ុន:	អត់មានទៅណា ។

សេងគា:	នៅជាអ្នកមូលដ្ឋាននៅស្រុកស្គន់ទៅ?

ប៊ុន:	នៅហ្នឹងទៅ ។

សេងគា:	គេអត់មានធ្វើបាបអីទេ?

ប៊ុន:	អត់មានទេ គេចង់ធ្វើបាបដែលតែគន់បុណ្យគេមិនយកទៅណា គេហៅទៅឃុំដែលកាលតែខ្ញុំ ថាអត់ទៅទេ ថាស្លាប់ៗនិងស្រុកហ្នឹងតែម្តងទៅ ។

សេងគា៖ ចឹងឪពុកម្តាយអ៊ំ?

ប៊ុន៖ ឪពុកម្តាយអត់មានទេ គាត់ស្លាប់តាំងពីមុនសម័យខ្មែរក្រហមហ្នឹង ។

សេងគា៖ បាទ ។

ប៊ុន៖ ធម្មតាយើងធ្វើបុណ្យធ្វើទានវាគគ្រឹកគគ្រេងចឹងណាស់ ។

សេងគា៖ ចឹងមុនខ្មែរក្រហម?

ប៊ុន៖ បាទ!មុនខ្មែរក្រហម ។

សេងគា៖ សម័យលន់ នល់ឬមុនលន់ នល់ទៀតឪពុកម្តាយអ៊ំ?

ប៊ុន៖ មុន ។

សេងគា៖ មុនទៀត ចឹងអ៊ំរត់ទៅក្រចេះអីនោះ?

ប៊ុន៖ រត់ទៅតាំងពីសង្គមនោះ ។

សេងគា៖ អ! ។

ប៊ុន៖ មិនរត់ទេ ទៅរកស៊ីធម្មតាហ្នឹង ។

សេងគា៖ បាទ!ចឹងមកដល់ស្អន់នេះឪពុកម្តាយសម្លាប់អស់ហើយអ៊ំណឹង?

ប៊ុន៖ នៅខ្ញុំមកផ្ទាល់ខ្លួនតែម្តងស្លាប់នៅដៃខ្ញុំតែម្តង ។

សេងគា៖ ចឹងឪពុកម្តាយអ៊ំនៅរស់ទេ?

ប៊ុន៖ នៅរស់ ។

សេងគា៖ ចឹងអ៊ំថាស្លាប់មុនប៉ុល ពតមុនលន់ នល់ ពេលរត់ហ្នឹង៧៩អះ!៧៥ណាស់?

ប៊ុន៖ ប៉ុល ពតណា ប៉ុល ពតអត់ទាន់មានទេ កាលមកនេះ ។

សេងគា៖ ឆ្នាំ៧៥ប៉ុល ពតមានហើយអ៊ំ?

ប៊ុន៖ វាស្រពិចស្រពិល ។

សេងគា៖ បាទ!ឆ្នាំ៧៦ហ្នឹងពេញតែម្តង ប៉ុល ពតកាន់អំណាច?

ប៊ុន៖ អត់មានទេ ។

សេងគា៖ បាទ ។

ប៊ុន៖ អត់មានអីទេ ស្រុកខ្ញុំ ។

សេងគា៖ បាទ!ចឹងឪពុកអ៊ំនៅរស់ទេ ទើបស្លាប់សម័យខ្មែរក្រហមដែរទេ?

ប៊ុន៖ ស្លាប់ក្នុងសម័យខ្មែរក្រហមហ្នឹង ។

សេងគា៖ គាត់ស្លាប់ដោយសារអីអ៊ំឈឺ?

ប៊ុនៈ ឈឺគាត់ឈឺ ។

សេងគាៈ មានគេប្រើធ្វើបាបគេវ៉ៃដែលទេ?

ប៊ុនៈ អត់មានវ៉ៃជុំទាត់ធាក់អីទេ ។

សេងគាៈ បាទ ។

ប៊ុនៈ មកហ្នឹងខ្ញុំនិយាយឲ្យអស់ទៅ ស្រុកស្អុនណាស់បើយួនចូលទៅភូមិចឹងខ្មែរគេអូហ្នឹងវាប្រហូតពីស្អុនទៅរហូតខ្មែរគេអូខ្មែរទូរស័ព្ទគេអូគេហ្នឹង ។

សេងគាៈ បាទ ។

ប៊ុនៈ តែដេកបានតែមួយយប់ទេ យប់ប្រាស់ទៅនោះពួកខ្មែរក្រហមវាធ្វើបាបវាវ៉ៃហ្នឹងណាស់ ។

សេងគាៈ បាទ ។

ប៊ុនៈ ជួនកាលដាក់មីន ។

សេងគាៈ តែគ្រួសារអ៊ីអត់អីទេ?

ប៊ុនៈ អត់អីទេ ដូចយើងសព្វថ្ងៃនេះ ។

សេងគាៈ ឪពុកម្តាយអ៊ីស្លាប់នៅឆ្នាំ៧០ប៉ុន្មាន ស្លាប់មុនកូនប្រុសអ៊ីឬក្រោយកូនប្រុសអ៊ី?

ប៊ុនៈ ស្លាប់មុន ។

សេងគាៈ មុនចឹង៧៦អ៊ី?

ប៊ុនៈ ៧៦-៧៧ហ្នឹង រត់មកពីក្រចេះវិញ មកពីក្រចេះមកនៅព្រែកចារហ្នឹង ។

សេងគាៈ ចឹង?

ប៊ុនៈ មកស្លាប់នៅព្រែកចារហ្នឹងទាំងអស់ទាំងម្តាយទាំងឪពុកហ្នឹងណាស់ ។

សេងគាៈ កាលហ្នឹងមានបានយកទៅកប់អីត្រឹមត្រូវទេអ៊ី?

ប៊ុនៈ មេនមានតែតើមេនវត្តនោះដុតរំលាយគាត់ហ្នឹង ។

សេងគាៈ យកមេនមកដុត?

ប៊ុនៈ ហ្នឹងមេនលោកហ្នឹង ។

សេងគាៈ ចឹងមានលោកដែលកាល៧៦ហ្នឹងមានលោកដែរ?

ប៊ុនៈ មានតែមានលួចលាក់និងណា ។

សេងគាៈ អ!ធ្វើបុណ្យអីទៅ?

ប៊ុនៈ ធ្វើបុណ្យទៅធ្វើបុណ្យហ្នឹងមានគគ្រឹកគ្រែងប៉ុន្មាន ។

សេងគាៈ ចឹងអ៊ីគេឲ្យធ្វើអីទៅកាលឆ្នាំ៧៦-៧៧ហ្នឹង?

ប៊ុនៈ គ្មានធ្វើអីទេ ។

សេងគាៈ ចូលសហករណ៍ណាអីក្រុមកងចល័តណាអី?

ប៊ុនៈ មើលកាលខ្មែរក្រហមខ្ញុំគេឲ្យដាំបាយ ។

សេងគាៈ ចឹងអ៊ីនៅខាងដាំបាយ?

ប៊ុនៈ បាទ! នៅខាងដាំបាយប្រពន្ធខ្ញុំស្ទូស្ទុកអីទៅ ។

សេងគាៈ ចឹងខាងចុងភៅដូចគ្នា?

ប៊ុនៈ បាទ! ខាងចុងភៅយើងខ្មែរក្រហមហ្នឹងណាស់ មានធ្វើអីទេ ។

សេងគាៈ ហើយកូនស្រីអ៊ីបែកគ្នាទៅ ទៅធ្វើទាហានបាត់ហើយ?

ប៊ុនៈ ហ្នឹងហើយកូនបែកទៅ ហើយគោអូររាំងឪមកទាំងហ្វូងៗ ហើយខាងភូមិអំពិលហ្នឹងចាប់មកមួយពីរទៅយកមកធ្វើទៅអាហ្នឹងស្រេចនិងគេធ្វើអីធ្វើទៅ ស្ងោស៊ុបទៅ ។

សេងគាៈ បាទ ។

ប៊ុនៈ ទាំងព្រឹកទាំងល្ងាចដាំបាយបីបួនខ្ទះ ។

សេងគាៈ ហ្នឹងនៅអូររាំងឪនៅណា?

ប៊ុនៈ នៅអូររាំងឪ ។

សេងគាៈ មិនទាន់មកស្គន់ទេ ទាល់បែកហើយបានមកស្គន់?

ប៊ុនៈ បាទ! ទាល់តែបែងហ្នឹង ។

សេងគាៈ ចឹងកាលសម័យប៉ុល ពតអ៊ីនៅស្គន់រហូតទេ អះ! នៅអូររាំងឪរហូតទេបែកហើយបានអ៊ីមកហ្នឹង?

ប៊ុនៈ ដល់បែកហើយបានអ៊ីមក មកហ្នឹងដើររហូតដើរពីអូររាំងឪហ្នឹងមកដើរគ្នាពីរបីនាក់កូនស្រីមួយនិងខ្ញុំប្រពន្ធដើររែកជ្រូកប៉ុននេះ រែកជ្រូកគេឲ្យធ្វើទ្រុងនិងមាន់បួនប្រាំ ។

សេងគាៈ កាលហ្នឹងអ៊ីហូបបរបូរទេអត់មានខ្វះអីប៉ុន្មានទេ តែអ៊ីនៅចុងភៅចឹងមិនខ្វះអីហូបទេ?

ប៊ុនៈ ឲ្យហូបតែមិនឲ្យយកមកផ្ទះហូបនិងកន្លែងហូបទៅកុំយកមកផ្ទះ យកមកផ្ទះគេឃើញដកយកមកវិញណាស់ ។

សេងគាៈ ចឹងឪពុកម្ដាយអ៊ីនៅហ្នឹងហូបគ្រប់គ្នាទៅ?

ប៊ុនៈ អត់ទេ គាត់នៅស្រុកនេះតើ ។

សេងគាៈ ចឹងគាត់អត់ទៅទេ គាត់នៅស្រុកគាត់ទេ?

ប៊ុនៈ បាទ! នៅ ។

សេងគា: ទៅតែអ៊ឹនិងប្រពន្ធកូនទេ?

ប៊ុនៈ នៅប្រពន្ធកូនទេ ។

សេងគា: កាលហ្នឹងពីណាគេជាប្រធានសហករណ៍នៅហ្នឹងអ៊ឹ?

ប៊ុនៈ ឈ្មោះ អា ញ៉ាញ់ អាញ៉ាញ់បានតែពីរថ្ងៃគេបាញ់ចោលទៅ ។

សេងគា: ម៉េចកាចពេក?

ប៊ុនៈ កាចពេកដល់ស្លាប់ទៅមានអី ។

សេងគា: អ្នកណាគេជាអ្នកបាញ់ចោលអ៊ឹប្រជាជនលួចបាញ់?

ប៊ុនៈ ពួកគ្នាវាហ្នឹង ពួកទ័ពគ្នាវាហ្នឹងវាឃោរឃៅពេកណាស់ ។

សេងគា: បាទ!ចឹងដល់បាញ់ទៅឡើងពីណាគេជំនួសវិញ?

ប៊ុនៈ មិនដឹងជាពីណាខ្ញុំភ្លេចហើយយូរហើយវាភ្លេចអស់ហើយ ។

សេងគា: ចឹងកាលនៅហ្នឹងអ៊ឹមានឃើញគេយកមនុស្សទៅសម្លាប់អីទេ?

ប៊ុនៈ មានដែរ ។

សេងគា: អ៊ឹឃើញដែរ?

ប៊ុនៈ គាត់ជាអ្នកក្តាប់អូររាំងឪហ្នឹង ស្លាប់នៅវត្តហ្នឹងគ្រាន់តែបាយគ្រាន់តែសាច់គ្នាស៊ីសាច់ធម្មតា ហ្នឹងយកគ្នាទៅវ៉ៃចោលទៅ ។

សេងគា: អ្នកណាគេជាអ្នកយកទៅ អ៊ឹមានដឹងទេ?

ប៊ុនៈ ប្រធានស្អីគេខ្ញុំមិនសូវស្គាល់ផង ។

សេងគា: ប្រធានកង?

ប៊ុនៈ បាទ!ប្រធានកងប្រធានភូមិពួកគេហ្នឹង ។

សេងគា: តែអ៊ឹមិនបានស្គាល់ឈ្មោះទេ?

ប៊ុនៈ ស្គាល់តែឥឡូវវាភ្លេចអស់ហើយវាយូរឆ្នាំហើយ ។

សេងគា: ចឹងឃើញចាប់មុខអ៊ឹតែម្តងគេចោទ?

ប៊ុនៈ ចាប់យកទៅ ។

សេងគា: គេចោទថាម៉េចអ៊ឹកាលហ្នឹង?

ប៊ុនៈ ចោទថាឯងលួចអីយកទៅឲ្យខ្មាំងអីស៊ីណាស់ ។

សេងគា: លួចពីកន្លែងរោងបាយអ៊ឹ?

ប៊ុនៈ បាទ!ហ្នឹងហើយ ។

សេងគា៖ គេយកទៅដាក់វត្តអីគេ អីវត្តអូររាំងឪហ្នឹង?

ប៊ុន៖ វត្តអូររាំងឪ ។

សេងគា៖ កាលហ្នឹងអ្នកគ្រប់គ្រងខាងនិរតីឬខាងណាអ៊ឺ?

ប៊ុន៖ ខាងនិរតីចឹងហើយ ។

សេងគា៖ ពួកខាងតាកែវ?

ប៊ុន៖ បាទ ។

សេងគា៖ ពួកហ្នឹងកាចៗទេអ៊ឺ?

ប៊ុន៖ យី!កាចណាស់ មុខមើលតែចាក់ឈាមចឹងហើយភ្នែកវាដូចភ្នែកនេះចឹង ។

សេងគា៖ ក្រហមៗ?

ប៊ុន៖ បាទ!ក្រហមដូចនេះចឹង ឃើញខ្លាចវាសម្ដីងមុខខ្ញុំមិនហ៊ានមើលមុខវាចំទេ ។

សេងគា៖ មានស្គាល់ថាឈ្មោះអីទេអ៊ឺ?

ប៊ុន៖ វាភ្លេចអស់ហើយ បើនៅប្រាប់តែភ្លេចអស់ហើយយូរឆ្នាំហើយតាំងពីខ្ញុំនៅស្រុកតឡូវមកស្រុកនេះ ។

សេងគា៖ ប៉ុន្តែអ៊ីនិងប្រពន្ធកូនមិនដែលមានគេធ្វើបាបអីទេអ៊ឺ?

ប៊ុន៖ មានអីទេ ធម្មតាហ្នឹង ។

សេងគា៖ អ៊ឹជាអ្នកដាំបាយហូបតែហូបគ្រប់គ្រាន់ទេ?

ប៊ុន៖ មានអី ។

សេងគា៖ អត់មានគេអត់ដូចនៅកន្លែងផ្សេងហូបបបរអី?

ប៊ុន៖ អត់ទេ ស្រុកអូររាំងឪហ្នឹងបើសិនជាបបរ បបរដាក់កញ្ច្រោងបាន កញ្ច្រោងក្រឡាររង្វើលៗដាក់បានអាហ្នឹង អា ញ៉ាំញ៉ាំដែរ យូរៗប្រែទៅជាបបរ ។

សេងគា៖ ចឹងគេលួចបាញ់ទៅ?

ប៊ុន៖ ហ្នឹងហើយលួចបាញ់ចាលទៅ ។

សេងគា៖ ហើយហូបបាយវិញទៅ?

ប៊ុន៖ ហូបបាយទៅ ។

សេងគា៖ ចឹងអ៊ីនៅហ្នឹងរហូតពី៧៦ដល់៧៩អ៊ឹណឹង?

ប៊ុន៖ ហ្នឹងហើយ ។

សេងគា: ចឹងអ៊ឺមានបានឃើញកន្លែងគេដាក់គុកដាក់ច្រវ៉ាក់អីអ៊ឺមានឃើញទេ ធ្វើទារុណកម្មអីអត់មានឃើញទេ?

ប៊ុនៈ អត់មានឃើញទេ ព្រោះខ្ញុំមិនសូវដើរចំកន្លែងគុកហ្នឹង វាមានតែមិនដឹងដាក់កន្លែងណាកន្លែងណាទេ ខ្ញុំមិនសូវជ្រាតជ្រែកកន្លែងចឹង ។

សេងគា: ចឹងនៅពេលវៀតណាមចូលមកអ៊ឺឃើញមានសភាពការណ៍យ៉ាងម៉េចដែលនៅហ្នឹង?

ប៊ុនៈ អត់មានអីដែរ ។

សេងគា: ចឹងពេលវៀតណាមចូលមកមានប្រយុទ្ធគ្នាអីទេ?

ប៊ុនៈ អត់មាន ។

សេងគា: នៅខាងអូររាំងឪអត់មានទេ?

ប៊ុនៈ ខាងអូររាំងឪ ។

សេងគា: បាទ ។

ប៊ុនៈ អត់មានទេ អត់មានឃើញទេ មានចូលតែមិនមានឃើញប្រយុទ្ធ ។

សេងគា: ចឹងនៅពេលវៀតណាមចូលមកក្លាមអ៊ឺរត់មកនេះតែម្ដងឬក៏យ៉ាងម៉េចនៅទៀត?

ប៊ុនៈ នៅតើ ។

សេងគា: ចឹងនៅអូររាំងឪរហូតទាល់តែស្ងប់បានមក?

ប៊ុនៈ បាទ!ដល់ស្ងប់និងហើយបានមួយខែពីរខែ បានស្ងប់ហើយវាចេញអស់ខ្ញុំសុំគេមកស្រុកណាស់ មកអ៊ីខេត្តកំពង់ចាមនេះដើរមករហូតខ្ញុំបីនាក់ ដើរមកឆ្លងយើងទន្លេបិតហ្នឹង ចុងមានទាន់ស្ពានណា ឆ្លងសាឡាង សាឡាងគេដកយកទៅបាត់ឆ្លងទូកម៉ាស៊ីនយើងម្នាក់យកបីកំប៉ុងអង្ករណាស់ ។

សេងគា: បាទ ។

ប៊ុនៈ និយាយហួសមួយកំប៉ុងអង្ករក្នុងម្នាក់ ។

សេងគា: ចឹង?

ប៊ុនៈ បាទ!អស់បីកំប៉ុងឆ្លងមកដល់កំពង់ចាមហ្នឹង ។

សេងគា: ចឹងអ៊ឺស្ពាយអង្ករពីនោះមកដែរ ។

ប៊ុនៈ គេឲ្យមកអ្នកស្រុកគេឲ្យ គេលួចឲ្យមកណា ។

សេងគា: កាលហ្នឹងអ៊ឺអត់មានស្គាល់គណៈឃុំគណៈស្រុកអីទេ?

ប៊ុនៈ អត់ស្គាល់ទេ ជំនាន់ហ្នឹងមិនដឹងជាមួយណាៗទេ យូរឆ្នាំហើយនៅជាប់ស្គាល់ឥឡូវភ្លេច ។

សេងគា: បាទ ។

ប៊ុន: ចឹងក្មួយឯងមកពីខាងណាវិញ?

សេងគា: ខ្ញុំមកពីផ្ទះមេភូមិ អះ!មេឃុំ ។

ប៊ុន: មេឃុំណា?

សេងគា: មេឃុំអូរដារ ។

ប៊ុន: មេឃុំនេះ?

សេងគា: បាទ ។

ប៊ុន: សៀនហ្នឹង?

សេងគា: បាទ!ខ្ញុំមកពីខេត្តគេងហ្នឹងបានមួយយប់ហើយអ៊ី ។

ប៊ុន: មកដេកហ្នឹង?

សេងគា: បាទ!អ៊ីមកដេកផ្ទះសំណាក់នៅជិតកាស៊ីណូនេះ ចុះមកធ្វើការនៅស្រុកហ្នឹង ។

ប៊ុន: មិនទាន់ចុះគ្រប់ទេ?

សេងគា: នៅអ៊ីទើបធ្វើបានពីរឃុំ ។

ប៊ុន: ចឹងទើបបានពីរឃុំទេ?

សេងគា: បាទ ។

ប៊ុន: ម្សិញមិញធ្វើនៅអូរដារ?

សេងគា: ម្សិញមិញធ្វើនៅខាងមុខជិតផ្លូវបំបែក ។

ប៊ុន: ចឹងអូរដារហ្នឹង ។

សេងគា: ចឹងបងប្អូនដែលថាស្លាប់ហ្នឹងស្លាប់តាំងពីពេលណាមកអ៊ី?

ប៊ុន: ស្លាប់តាំងពីសង្គម ។

សេងគា: អរ!ស្លាប់តាំងពីសង្គមទេ?

ប៊ុន: បាទ!ស្លាប់តាំងពីសង្គមម៉េះ ។

សេងគា: ចឹងមិនមែនសម័យខ្មែរក្រហមទេ?

ប៊ុន: មិនមែនទេ ។

សេងគា: ចឹងបងប្អូនអ៊ីអត់សូវមានគេធ្វើបាបអីទេ?

ប៊ុន: អត់មាន មានបងមួយអាហ្នឹងមានប្រពន្ធវាឃោឃៅពេក គេចាប់យកទៅវៃចោលបងខ្ញុំ ។

សេងគា: បងណាបងទីមួយហ្នឹង?

ប៊ុនៈ បងទី១ ។

សេងគាៈ យោយៅយ៉ាងម៉េចទៅ?

ប៊ុនៈ យោយៅថាគេលួចសាច់គោសាច់ក្របីយកមកលក់ហ្នឹងណាស់ ម៉ាជំនាន់ហ្នឹង ។

សេងគាៈ គាត់ជាអ្នកលួចយកមកលក់?

ប៊ុនៈ បាទ!ហ្នឹងហើយ បានគេយកទៅវ៉ៃចោលហ្នឹង ។

សេងគាៈ សម័យខ្មែរក្រហមហ្នឹង?

ប៊ុនៈ សម័យខ្មែរក្រហមពេញនិយម ។

សេងគាៈ ចឹងអ្នកផ្សេងៗស្លាប់មុនបងឬក្រោយបងទេ?

ប៊ុនៈ ក្រោយអាហ្នឹងយកទៅវ៉ៃចោលក្រោយទេ ។

សេងគាៈ ចឹងសម័យខ្មែរក្រហមដែរ?

ប៊ុនៈ សម័យខ្មែរក្រហមដូចគ្នា ។

សេងគាៈ ចឹងបងប្អូនអ៊ីហ្នឹងសុទ្ធតែសម័យខ្មែរក្រហមដែលទេចឹង?

ប៊ុនៈ មានមុនមានក្រោយ ។

សេងគាៈ ក្រោយខ្មែរក្រហមហើយ?

ប៊ុនៈ បាទ!ក្រោយខ្មែរក្រហមហ្នឹង ។

សេងគាៈ ចូល៨០ដាងហើយអ៊ី?

ប៊ុនៈ ៨០ហើយកាលឆ្នាំទៅស្លាប់បងម្នាក់និងស្លាប់ចប់ខ្មែរក្រហមហើយ គាត់ស្លាប់និងឈឺគាត់ឡើងឈាម ។

សេងគាៈ ចឹងផុតពីហ្នឹងមានអ្នកស្លាប់ដោយសារអីអីមានដឹងទេ?

ប៊ុនៈ មានអីទេ ស្លាប់ធម្មតាហ្នឹងឈឺជំងឺហ្នឹងណាស់ ។

សេងគាៈ ក្រោយខ្មែរក្រហមហើយទេ?

ប៊ុនៈ ស្លាប់ក្រោយ ។

សេងគាៈ តែមានតែបងមួយគេចោទថាខ្មាំងគេចោទថាលួចសាច់គោទៅលក់អីចឹង?

ប៊ុនៈ ហ្នឹង ។

សេងគាៈ កាលហ្នឹងនៅឆ្នាំណាអ៊ីបងស្លាប់ហ្នឹង?

ប៊ុនៈ ឆ្នាំណាទេ តាំងពីខ្មែរក្រហមហ្នឹងមក ។

សេងគាៈ ៧៨-៧៩ហ្នឹង?

ប៊ុនៈ ៧៨-៧៩ហ្នឹង ទេ ថា៩២-៩៣ចុះ ។

សេងគាៈ ចឹង៩០ជាងហើយ?

ប៊ុនៈ ៩០គត់ចុះ ព្រោះខ្ញុំទៅពីអូររាំងឪហ្នឹងទៅ៧៥-៧៦ហ្នឹង ។

សេងគាៈ អ៊ីនៅអូររាំងឪហ្នឹងគេឲ្យដាំបាយរហូតតែម្តងអ៊ី?

ប៊ុនៈ ដាំបាយទាំងប្រពន្ធទាំងអស់ ។

សេងគាៈ ចុះកូនស្រី?

ប៊ុនៈ កូននៅតូចឃ្វាលក្របីឃ្វាលគោ ។

សេងគាៈ ចឹងឃ្វាលក្របីឃ្វាលគោហ្នឹង?

ប៊ុនៈ កូនខ្ញុំហ្នឹងគ្មានខ្វាចពីណាទេ ឃ្វាលគោក្របីហ្នឹងអត់ខ្វាច ។

សេងគាៈ ចឹងអ៊ីថាចាប់ធ្វើទាហាន ទាហាន៨០ជាងហើយតើអ៊ី?

ប៊ុនៈ ៨០ ។

សេងគាៈ ចឹងកូនប្រុសអ៊ីដែលស្លាប់ហ្នឹងឆ្នាំ៨០ជាងដែលឬយ៉ាងម៉េច?

ប៊ុនៈ ប្រហែលជា៧០ទេ?

សេងគាៈ ៧០ជាងទេ?

ប៊ុនៈ បាទ ។

សេងគាៈ ចឹងកូនអ៊ីស្លាប់បានប៉ុន្មានឆ្នាំបានដឹងថាកូនអ៊ីស្លាប់?

ប៊ុនៈ ស្លាប់ហ្នឹងវាចូលមកហ្នឹងហើយវាផ្តាច់ខ្លួនហើយ ។

សេងគាៈ ចឹងផ្តាច់ខ្លួនហើយបានស្លាប់?

ប៊ុនៈ បាទ!ផ្តាច់ខ្លួនហើយវាស្លាប់ពីនោះ ផ្តាច់ខ្លួនមកហ្នឹងណាស់ប្រហែលជាពីរឆ្នាំបី ។

សេងគាៈ ចឹង៩០ជាងហើយ?

ប៊ុនៈ ហ្នឹងហើយ៩០ជាង ។

សេងគាៈ មិនមែន៧៩ទេ?

ប៊ុនៈ វាទៅកំពង់ចាមហ្នឹង ។

សេងគាៈ ចឹងអ៊ីមិនសូវចាំមេដឹកនាំអីចឹងសួរទៅអ៊ីមិនចាំឈ្មោះអីចឹងអ៊ីភ្លេចហើយ?

ប៊ុនៈ ហ្នឹងហើយវាច្រើនភ្លេចវាមិនច្រើនចាំដូចក្មេងថា វាមិនស្គាល់ឈ្មោះស្គាល់គេណា ។

សេងគាៈ បាទ ។

ប៊ុនៈ ដល់យូរទៅវាភ្លេចដែរ ។

សេងគាៈ ចឹងចុងក្រោយអ៊ីមានអីចង់សួរខ្ញុំវិញទេអ៊ី ចង់និយាយអ្វីដែលខ្ញុំមិនទាន់បានសួរនិយាយប្រាប់ខ្ញុំទេ ?

ប៊ុនៈ មានអី ។

សេងគាៈ ចឹងអ៊ីអាចនិយាយរឿងរ៉ាវប្រវត្តិខ្មែរក្រហមដែលបានជួបប្រទះឲ្យខ្ញុំស្តាប់បន្តិចបានទេអ៊ី ចង់ដឹងពីមុនមករឿងរ៉ាវយ៉ាងម៉េចខ្លះៗខ្ញុំសួរទៅខ្លាចអ៊ីពិបាកឆ្លើយចង់ឲ្យអ៊ីរៀបរាប់ខ្លួនឯង?

ប៊ុនៈ ខ្ញុំមិនដឹងឆ្លើយមិនដឹងសួរយ៉ាងម៉េចទេនេះ សើច...។

សេងគាៈ ខ្ញុំចង់ឲ្យអ៊ីរៀបរាប់កាលសម័យខ្មែរក្រហមណាស់?

ប៊ុនៈ បាទ ។

សេងគាៈ ខ្ញុំសួរទៅខ្លាចអ៊ីពិបាកឆ្លើយអ៊ីភ្លេចមុនភ្លេចក្រោយចឹង ខ្ញុំចង់ថាអ៊ីនឹកឃើញខ្លួនឯងនិយាយទាំងអស់ សម័យខ្មែរក្រហមយ៉ាងម៉េចខ្លះអ៊ី ជួបរឿងអីខ្លះ?

ប៊ុនៈ អត់មានជួបអីទេ អត់មានជួបសង្គ្រាមអត់មានជួបអីទេ ។

សេងគាៈ ចឹងសុខសាន្តរហូត?

ប៊ុនៈ បាទ!សុខសាន្តរហូតគេវៃគ្នានោះវៃទៅខ្ញុំនៅនេះវៃទៅ ជួនណាខ្ញុំដើរពីស្រុកមកហ្នឹងទៅព្រៃហ្នឹងគេមានធ្វើបាបធ្វើអី ពេលទៅគេសួរថាអ៊ីមកពីណា ខ្ញុំថាមកពីដាក់ទឹកប្រាំងបង្ហូរទឹកប្រាំងបង្ហូរដាក់ស្រូវ តែប៉ុណ្ណឹងគេចូលព្រៃវៀញទៅ ឯងចូលផ្ទះមកមានតែប៉ុណ្ណឹងអត់មានទៅសួរអីទេ មានសួររឿងរ៉ាវថាស្អីៗអត់ ។

សេងគាៈ ចឹងរឿងរ៉ាវអ៊ី អ៊ីមិនសូវចាំទេ?

ប៊ុនៈ បាទ!អត់មានទេ អត់សូវចាំទេ ។

សេងគាៈ បាទ ។

ប៊ុនៈ ខ្ញុំមិនសូវចាំទេ ។

សេងគាៈ ចឹងអ៊ីតាំងពីមក មកនៅនេះអ៊ីនៅជាប់រហូតទៅ?

ប៊ុនៈ នៅជាប់ទៅ១០ឆ្នាំជាងហើយ កាលមកកូនមកយក៩២ ។

សេងគាៈ បាទ ។

ប៊ុនៈ កាលផ្តាច់ខ្លួនហ្នឹងមកនៅហ្នឹងនៅប្រទ្រុះប្រទ្រះនៅឡើយទេ មិនទាន់ចប់ទេខ្មែរក្រហមនៅឡើយទេ ។

សេងគាៈ កូនអ៊ីមកពីណាមកផ្តាច់ខ្លួន គាត់មកធ្វើទាហានរត់មកហ្នឹង?

ប៊ុនៈ គាត់ជិះឡានថៃដូចប្រធានភូមិសុនហ្នឹងដែរ ។

សេងគា: គាត់មកជាមួយប្រធានភូមិសុនដែលកូនអ៊ី?

ប៊ុន: មកជាមួយគ្នាហ្នឹង តែមកមុនក្រោយ មកហ្នឹងព្រៃណែន។

សេងគា: អ៊ីនៅស្រុកទេ កូនអ៊ីបែកគ្នាមកហើយ?

ប៊ុន: ខ្ញុំនៅស្រុកនោះទេ ជាមួយប្រពន្ធនោះទេ។

សេងគា: អ៊ីបែកកូនប៉ុន្មានឆ្នាំទៅអ៊ី?

ប៊ុន: បែកហ្នឹងចូល១០ឆ្នាំ អះ!៥ឆ្នាំជាងហើយ។

សេងគា: ពេលសម័យខ្មែរក្រហមហ្នឹងបែកគ្នារហូតទៅអ៊ី?

ប៊ុន: បែកគ្នារហូតទៅ អាហ្នឹងរត់ចូលព្រៃនៅខេត្តកំពង់ចាមណាស់។

សេងគា: បាទ។

ប៊ុន: ស្តាប់មិនបាន....។

សេងគា: កូនអ៊ីផ្តាច់ខ្លួនហើយចាប់ដីអីហើយបានមកហៅអ៊ីមកនៅជាមួយទៅ?

ប៊ុន: ហ្នឹងហើយដីចែកចែកដីចំការខ្លះ ដីផ្ទះខ្ញុំនៅខាងក្រោយនេះ ខ្ញុំនៅក្រោយគេណាស់។

សេងគា: បាទ។

ប៊ុន: បានទិញដីគេនៅមុខ ទិញម៉ារ៉ៃ២០០០បាត។

សេងគា: បាទ។

ប៊ុន: ថ្លៃណាស់ម៉ាជំនាន់ហ្នឹង ហើយមកហ្នឹងកូនប្រសាកាប់ឫស្សីដើរលក់ ដើរលក់ដល់ថៃកាលហ្នឹងនិយាយថាអត់មានផ្លូវចេះទេ ផ្លូវមានតែផ្លូវលំដានជើងប៉ុននេះដើរទៅវេញ ហើយក្រហីងក្រហូងមានដីស្អាតចេះណាអត់មានទេ។

សេងគា: ចឹងកាលអ៊ីមកនៅហ្នឹងអីមានមនុស្សមករស់នៅច្រើនទេ កាល៩២ហ្នឹង?

ប៊ុន: មានច្រើន។

សេងគា: មានច្រើនដែរ?

ប៊ុន: នៅរង្គើល។

សេងគា: នៅរង្គើល?

ប៊ុន: ខ្សែមនេះក៏រង្គើលផ្ទះពីរបីខ្សែមកាលខ្ញុំមកហ្នឹង។

សេងគា: ចឹងសុទ្ធតែព្រៃអ៊ី?

ប៊ុន: ឥឡូវនេះ។

សេងគា: អត់ទេកាលពីមុន?

ប៊ុនៈ	មុនសុទ្ធតែព្រៃ   នៅនោះក៏ព្រៃតែព្រៃវាដុំៗដល់ឥឡូវវាស្រឡះអស់ហើយ ធ្វើផ្ទះអស់ហើយ ហើយមកយើងផ្សារចាស់ហ្នឹងមានផ្ទះណាមានផ្ទះប្រហែលជា១០ចុះ     បានជាខ្ញុំនៅយូរៗ ទៅផ្ទះដីធំនេះធ្វើផ្ទះទៅ  តាមនេះផ្លូវមានផ្លូវអាត្រាក់នេះហើយអណ្ដៅដានត្រឹមៗនេះ ។

សេងគា:	ចឹងខ្ញុំអត់មានអីសួរអ៊ីទៀតទេ  អរគុណអ៊ីច្រើន  អ៊ីអត់មាននិយាយប្រាប់ខ្ញុំទៀតទេ ។

ប៊ុនៈ	អត់ទេ ។

សេងគា:	ចឹងអ៊ីជំរាបលាអរគុណ ។

ប៊ុនៈ	បាទ ។

**ចប់**